**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ១[illegible]២...សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការលុបនិងបង្កើតបន្ថែមគណនីនិងអនុគណនីនៃប្លង់គណនេយ្យថវិកា របស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹតលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855 23 427 798

- បានឃើញអនុក្រឹត្យលេខ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការតម្លើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ០០៤ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិការបស់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-** ត្រូវបានលុបគណនីនិងអនុគណនីក្នុងប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានឈ្មោះនិងលេខសម្គាល់ដូចខាងក្រោម÷

**១**-លុបគណនីដែលស្ថិតនៅក្នុងគណនី "អាករលើសេវាដែលបានកំណត់ " មានលេខសម្គាល់៧004 ស្ថិតនៅក្នុងជំពូក "ចំណូលសារពើពន្ធក្នុងស្រុក" មានលេខសម្គាល់៧0 មានឈ្មោះនិងលេខសម្គាល់ដូចខាងក្រោម÷

-អនុគណនី "អាករលើកាស៊ីណូ" មានលេខសម្គាល់៧00៤១

-អនុគណនី "អាករលើឆ្នោត" មានលេខសម្គាល់៧00៤២

-អនុគណនី "អាករលើល្បែងភ្នាល់ផ្សេងៗ" មានលេខសម្គាល់៧00៤៣

-អនុគណនី "អាករអាកាសយានដ្ឋាន" មានលេខសម្គាល់៧00៤៤។

**២**-លុបអនុគណនីដែលស្ថិតនៅក្នុងគណនី "អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តសកម្មភាព " មានលេខសម្គាល់៧00៥ ស្ថិតនៅក្នុងជំពូក "ចំណូលសារពើពន្ធក្នុងស្រុក" មានលេខសម្គាល់៧0 មានឈ្មោះនិងលេខសម្គាល់ដូច ខាងក្រោម÷

-អនុគណនី "ចំណូលពីអាជ្ញាបណ្ណនាំចេញ" មានលេខសម្គាល់៧00៥១

-អនុគណនី "ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក" មានលេខសម្គាល់៧00៥២

**៣**-លុបអនុគណនី "កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ" មានលេខសម្គាល់៧១0១៥ ស្ថិតនៅក្នុង គណនី "ពន្ធនិង

អាករលើការនាំចេញ" មានលេខសម្គាល់៧១០១ នៃជំពូក "ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស" មានលេខសម្គាល់៧១។

**ប្រការ២.-** បង្កើតបន្ថែមគណនី "កម្រៃប្រតិបត្តិការផ្សេងទៀត" មានលេខសម្គាល់៧៣០៦ ស្ថិតនៅក្នុងជំពូក "ផលទុនពីការលក់ផ្ទូលទ្រព្យសម្បត្តិនិងសេវា" មានលេខសម្គាល់៧៣។ គណនីលេខ៧៣០៦ មានអនុគណនីដូចខាងក្រោម÷

- -អនុគណនី "ចំណូលកាតព្វកិច្ចពីកាស៊ីណូ" មានលេខសម្គាល់៧៣០៦១
- -អនុគណនី "ចំណូលកាតព្វកិច្ចពីឆ្នោត" មានលេខសម្គាល់៧៣០៦២
- -អនុគណនី "ចំណូលកាតព្វកិច្ចពីល្បែងភ្នាល់ផ្សេងៗ" មានលេខសម្គាល់៧៣០៦៣
- -អនុគណនី "ចំណូលពីអាកាសយានដ្ឋាន" មានលេខសម្គាល់៧៣០៦៤
- -អនុគណនី "ចំណូលពីអាជ្ញាបណ្ណនាំចេញ" មានលេខសម្គាល់៧៣០៦៥
- -អនុគណនី "ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក" មានលេខសម្គាល់៧៣០៦៦
- -អនុគណនី "កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ" មានលេខសម្គាល់៧៣០៦៧។

**ប្រការ៣.-** ប្រព្រឹត្តិកម្មនៃគណនី ÷

គណនីនិងអនុគណនីទាំងឡាយដែលមានឈ្មោះនិងលេខសម្គាល់ដូចនៅប្រការ២

ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលប្រមូលបានឬត្រូវប្រមូល ហើយមានការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលប្រមូលបានឬត្រូវប្រមូល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ប្រការ៤.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវបានទុកជានិរាករណ៍។

**ប្រការ៥.-** អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអង្គភាពថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៥

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ